FAIR FINANCE CAMBODIA
A MEMBER OF FAIR FINANCE ASIA

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

OXFAM

# ពិធីប្រកាសដាក់ឱ្យប្រើប្រាស់
# របាយការណ៍ស្រាវជ្រាវ
# ស្តីពី «ការផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គាំទ្រការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩»

**ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង១១:៣០ថ្ងៃត្រង់**

**ទីកន្លែង សណ្ឋាគារកាំបូឌីយ៉ាណា (រាជធានីភ្នំពេញ)**

## សេចក្តីផ្តើម

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាព ឈានមុខគេនៅក្នុងប្រទេសកម្ពុជា ដែលមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួន ១៨០ ស្ថាប័ន ជាសមាជិកកំពុងធ្វើការងារលើវិស័យអភិវឌ្ឍន៍ផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ គ.ស.ក បំពេញការងារក្នុងភាពជាដៃគូសម្រាប់អភិបាលកិច្ចល្អ បរិយាកាសអំណោយផល ភាពជាដៃគូប្រកបដោយបរិយាបន្ន និងនិរន្តរភាពរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា។

អង្គការ គ.ស.ក គឺជាសមាជិកមួយនៃសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌នៅកម្ពុជា (FFC) ដែលជាវេទិកាមួយដែលដឹកនាំដោយអង្គការអុកស្វាមកម្ពុជា (Oxfam) ក្រោមពាក្យស្លោក គំនិតផ្តួចផ្តើមហិរញ្ញវត្ថុយុត្តិធម៌អាស៊ីថ្នាក់តំបន់ ដើម្បីលើកកម្ពស់ចីរភាពហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ គម្រោងនេះ សហការអនុវត្តដោយស្ថាប័នចំនួន៧ គឺ អង្គការអុកស្វាមកម្ពុជា (Oxfam)[1] អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF)[2] អង្គការតម្លាភាពកម្ពុជា (TIC)[3] អង្គការសីលកា (SILAKA)[4] អង្គការអង្គការអាក់សិនអេតកម្ពុជា (AAC)[5] និងអង្គការ ផេកកម្ពុជា (PACT Cambodia)[6] ។

សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អាស៊ី (FFA)[7] គឺជាបណ្តាញនៃអង្គការសង្គមស៊ីវិលនៅអាស៊ី ដែលធ្វើការ ដើម្បីធានាថាស្ថាប័នហិរញ្ញវត្ថុនានា ដែលប្រតិបត្តិការនៅអាស៊ី មានតម្លាភាព និងគណនេយ្យភាព ចំពោះលក្ខណៈវិនិច្ឆ័យបរិស្ថាន សង្គម និងអភិបាលកិច្ច នៅក្នុងវិស័យហិរញ្ញវត្ថុ និងការសម្រេចចិត្តវិនិយោគរបស់ពួកគេ។ បច្ចុប្បន្នសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អាស៊ីកំពុងបំពេញការងារនៅថ្នាក់តំបន់ និងក្នុងប្រទេសចំនួនដប់ប្រទេស នៅទូទាំងអាស៊ីរួមមាន កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន ប៉ាគីស្ថាន ហ្វីលីពីន ថៃ វៀតណាម ឡាវ និងបង់ក្លាដេស។ សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អាស៊ី គឺជាបណ្តាញ

---

[1] Oxfam in Cambodia | The future is equal

[2] The NGO Forum on Cambodia

[3] Transparency International Cambodia (ticambodia.org)

[4] https://www.silaka.org/

[5] Action Aid Cambodia

[6] PACT Cambodia

[7] https://fairfinanceasia.org/



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
23/02/2023 22/02/2028
Symbol of Trust និមិត្តសញ្ញានៃការទុកចិត្ត

មួយនៃសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អន្តរជាតិ ដែលប្រតិបត្តិការនៅក្នុងតំបន់ចំនួនប្រាំមួយផ្សេងទៀតនៅទូទាំងពិភពលោក ក្រៅពី ប្រទេសចំនួនប្រាំបីរបស់សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អាស៊ី។

នៅឆ្នាំ២០២១ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានផ្តល់ជំនួយហិរញ្ញវត្ថុចំនួន ៣៣២ លានដុល្លារអាមេរិក ដើម្បីពង្រឹងការឆ្លើយតបនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា និងអភិវឌ្ឍឧស្សាហកម្មហិរញ្ញវត្ថុ ការកសាងហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងជួយកែលម្អបណ្តាញផ្លូវថ្នល់។ កញ្ចប់ហិរញ្ញប្បទាននេះ រួមមាន ៨២.០៥លានដុល្លារអាមេរិក សម្រាប់ដំណាក់កាលទី២ នៃគម្រោងកែលម្អបណ្តាញផ្លូវថ្នល់ ដើម្បីស្តារឡើងវិញនូវផ្លូវជាតិ និងផ្លូវខេត្តប្រវែង ៤៨គីឡូម៉ែត្រ ក្នុងខេត្តព្រៃវែង និងខេត្តកណ្តាល ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតាមច្រករបៀង ភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ (GMS)។ នៅចន្លោះឆ្នាំ២០២១ និងឆ្នាំ២០២២ លទ្ធផលពីគម្រោងបង្ហាញពី ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចប៉ះពាល់ដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ ការធ្លាក់ចុះនៃកម្រិតជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច ឬការកើនឡើងនៃជម្លោះសង្គមនៅថ្នាក់មូលដ្ឋាន។ ដូច្នេះ គោលនយោបាយ និងផែនការសកម្មភាពការពារសង្គមត្រូវបានទាមទារសម្រាប់ការទប់ស្កាត់បញ្ហាប្រឈមទាំងនេះ និងផលប៉ះពាល់ដែលកើតមានឡើងផ្សេងទៀត។

ដោយមានការគាំទ្រពី សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អាស៊ី សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា និងអង្គការអុកស្វាម, អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាបានចាត់តាំងក្រុមការងារនៃទីប្រឹក្សាឯករាជ្យ ដើម្បីធ្វើការសិក្សាលើ «ការផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គាំទ្រដល់ការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញនៅក្រោយវិបត្តិនៃជំងឺកូវីដ-១៩» ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២២ ដល់ខែឧសភា ឆ្នាំ២០២៣។ ការសិក្សាស្រាវជ្រាវនេះផ្តោតជាសំខាន់លើការលើកកម្ពស់សេដ្ឋកិច្ចប្រកបដោយចីរភាព និងបៃតង ការផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គាំទ្រដល់ការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញនៅក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ដោយពិនិត្យយ៉ាងស៊ីជម្រៅលើគម្រោងកែលម្អបណ្តាញផ្លូវ ដើម្បីស្តារឡើងវិញនូវផ្លូវជាតិ និងផ្លូវខេត្តប្រវែង ៤៨,៨ គីឡូម៉ែត្រក្នុងខេត្តព្រៃវែង និងខេត្តកណ្តាល ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតាមច្រករបៀង ភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ (GMS)។ របាយការណ៍សិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ និងត្រៀមខ្លួនជាស្រេចសម្រាប់ការដាក់ឱ្យប្រើប្រាស់ជាសាធារណៈ។

ដូច្នេះ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា បានរៀបចំពិធីប្រកាសដាក់ឱ្យប្រើប្រាស់របាយការណ៍ស្រាវជ្រាវស្តីពី **«ការផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គាំទ្រការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩» ដែលនឹងប្រព្រឹត្តិថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣** វេលាម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង ១១:៣០ថ្ងៃត្រង់ ទីកន្លែង សណ្ឋាគារកាំបូឌីយ៉ាណា (រាជធានីភ្នំពេញ) ។

## គោលបំណង

គោលបំណងនៃពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការរបាយការណ៍ស្រាវជ្រាវមានដូចខាងក្រោម៖

- ដើម្បីដើម្បីផ្សព្វផ្សាយរបាយការណ៍សិក្សាស្រាវជ្រាវ ស្តីពីការផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គាំទ្រការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩
- ដើម្បីពិភាក្សាអំពីអនុសាសន៍សំខាន់ៗ និងរបៀបប្រើប្រាស់វាសម្រាប់ការអភិវឌ្ឍន៍កាន់តែប្រសើរ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
23/02/2023 22/02/2028
Symbol of Trust និមិត្តសញ្ញានៃការទុកចិត្ត

**របៀបវារៈ**

| **ពេលវេលា** | **ខ្លឹមសារ** | **អ្នកទទួលខុសត្រូវ** |
|---|---|---|
| ៨:៣០-៩:០០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ៩:០០- ៩:១០ | ប្រកាសហេតុ និង គោលបំណងនៃកម្មវិធី | លោកស្រី **ប្រាក់ កែវគន្ធា**<br>អ្នកឯកទេសផ្នែកច្បាប់ គ.ស.ក |
| ៩:១០- ៩:២០ | មតិស្វាគមន៍ដោយនាយិកាប្រតិបត្តិ គ.ស.ក | លោកស្រី **លុយ ធារី**<br>ប្រធានកម្មវិធី គ.ស.ក |
| ៩:២០- ៩:៣០ | ចំណាប់អារម្មណ៍ដោយ អង្គការអុកស្វាម តំណាងសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា | លោក **សុខ ឃីម** ប្រធានគម្រោងគ្រប់គ្រងធនធានធម្មជាតិ អង្គការអុកស្វាម ជាតំណាងសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា |
| ៩:៣០- ៩:៥០ | **បទបង្ហាញ៖**<br>អំពីការរកឃើញសំខាន់ៗនៃរបាយការណ៍សិក្សាស្រាវជ្រាវ ស្តីពីការផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គាំទ្រការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩<br>សំណួរ & ចម្លើយ | លោក **ឈឹម ឈន់** ទីប្រឹក្សាឯករាជ្យ |
| ៩:៥០-១០:១៥ | **សម្រាកអាហារសម្រន់** | |
| ១០:១៥-១១:១៥ | កិច្ចពិភាក្សាពេញអង្គ ៖ តើយើងត្រូវយកអនុសាសន៍គន្លឹះក្នុងរបាយការណ៍ស្រាវជ្រាវនេះ សម្រាប់ការអភិវឌ្ឍន៍ បរិស្ថាន សង្គម និងអភិបាលកិច្ច ឱ្យកាន់តែប្រសើរ<br>វាគ្មិន៖<br>• **ឯកឧត្តម ផែន សុវិជ្ជានោ** រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• លោក **គីម សម្បត្តិ** មន្ត្រីជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គមនៃធនាគារអភិវឌ្ឍន៍អាស៊ី<br>• លោកស្រី Jhelum T. Thomas, អ្នកឯកទេសជាន់ខ្ពស់ផ្នែកគ្រប់គ្រងសាធារណៈនៃធនាគារអភិវឌ្ឍន៍អាស៊ី<br>• លោកស្រី Bernadette Victorio អ្នកដឹកនាំកម្មវិធីប្រចាំតំបន់នៃសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អាស៊ី (FFA)<br>• តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (បញ្ជាក់ជូនពេលក្រោយ)<br>• តំណាងធនាគារជាតិនៃកម្ពុជា (បញ្ជាក់ជូនពេលក្រោយ) | លោកស្រី **លុយ ធារី**<br>ប្រធានកម្មវិធី គ.ស.ក |
| ១១:១៥- ១១:៣០ | បូកសរុប និងបិទកម្មវិធី | លោក **ម៉ារ សុផល**<br>ប្រធានគ្រប់គ្រងកម្មវិធីនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) ជាតំណាងសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា |
| ១១:៣០ | **ពិសាអាហារថ្ងៃត្រង់** | |

**សម្គាល់៖** កិច្ចប្រជុំនេះបកប្រែជាភាសាខ្មែរ និងអង់គ្លេស។ អង្គការ គ.ស.ក សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈ និងពេលវេលា អាស្រ័យលើពេលវេលារបស់វាគ្មិន និងបញ្ហាផ្សេងៗ។ ឯកសារផ្សេងៗរួមទាំងរូបភាព និងខ្លឹមសារសំខាន់ៗ នឹងត្រូវបានដាក់បញ្ចូលជាសាធារណៈក្នុងគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គម តាមតំណភ្ជាប់ *http://www.ccc-cambodia.org/en/resources/event-archives*

*www.facebook.com/CCCsince1990* *www.youtube.com/CCCambodia*




www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia